## ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ១៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩

ពាក្យគន្លឹះ៖ បទភេរវកម្ម,ប្រើប្រាស់អាវុធខុសច្បាប់និងពាក់សំលៀកបំពាក់ខុសបទបញ្ជា

**<u>១.អង្គហេតុនិងដំណើរការនីតិវិធី</u>៖** ជនជាប់ចោទមានគ្នា៨នាក់ ត្រូវបានចោទពីបទភេរវកម្ម ប្រើប្រាស់អាវុធខុសច្បាប់និងពាក់សំលៀកបំពាក់ខុសបទបញ្ជា ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៥ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម មាត្រា៩៤នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា១នៃច្បាប់ស្តីពីការផ្តន្ទាទោសកាន់កាប់ និងពាក់សំលៀកបំពាក់ឯកសណ្ឋានខុសបទបញ្ជា។ តំណាងអយ្យការអមតុលាការ បានស្នើឲ្យចោទប្រកាន់ជនជាប់ចោទមួយចំនួន រំលត់បណ្តឹងអាជ្ញាលើជនជាប់ចោទពីររូប លើកលែងចោទប្រកាន់ជនជាប់ចោទមួយរូប បង្អង់បណ្តឹងអាជ្ញាលើជនជាប់ចោទ១រូប ព្រោះគ្មានសាវតាជាតិនិងបញ្ជូនសំណុំរឿងទៅតុលាការដើម្បីជំនុំជម្រះ។ តុលាការក្រុងភ្នំពេញ សម្រេចផ្តន្ទាទោសជនល្មើសមួយចំនួន និងសម្រេចឲ្យរួចផុតពីការចោទប្រកាន់លើជនជាប់ចោទមួយរូបពីបទភេរវកម្ម។ សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ១៦១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ តម្កល់សាលក្រមលេខ៣១ (ក) នៃតុលាការក្រុងភ្នំពេញ ប៉ុន្តែកែប្រែចំណុចទី១ និងទី២ជាថ្មីវិញ ដោយបន្ថយទោសដាក់ពន្ធនាគារពី១៥ឆ្នាំទៅ១០ឆ្នាំ។ តុលាការកំពូល បានទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១៦១ និងបង្វិលសំណុំរឿងព្រហ្មទណ្ឌទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

២.**សំអាងហេតុនៃសេចក្តីសម្រេចរបស់តុលាការកំពូល៖-** *១.យល់ឃើញថា ក្នុងការសួរចម្លើយជនជាប់ចោទ...ទាំងប្រាំមួយលើក មានតែការសួរចម្លើយមួយលើកប៉ុណ្ណោះនៅមុខចៅក្រមស៊ើបសួរមានវត្តមានមេធាវី ដូច្នេះការសួរចម្លើយជនជាប់ចោទពីបទឧក្រិដ្ឋ ដែលគ្មានវត្តមានមានមេធាវីនោះ គឺជាការរំលោភទៅនឹងមាត្រា១០នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងមាត្រា៧៦នៃច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ ហើយភ័ស្តុតាងដែលបានមកពីការសួរចម្លើយបែបនេះ ពុំអាចទទួលយកជាការបានឡើយ។* ***២.****យល់ឃើញថា មានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា បទល្មើសដែលកើតឡើង...ពុំមែនជាបទល្មើសជាក់ស្តែងទេ ប៉ុន្តែការចាប់ខ្លួនជនជាប់ចោទ...បែរជាពុំមានដីកាពីអាជ្ញាធរតុលាការ ហើយឃុំខ្លួនជនជាប់ចោទលើសថេរៈវេលាដែលច្បាប់បានកំណត់ទើបបញ្ជូនខ្លួនជនជាប់ចោទទៅអយ្យការអមតុលាការក្រុងភ្នំពេញ ដែលជាការរំលោភមាត្រា១០,១៣និង១៨នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។*

**កំណត់សំគាល់៖** ជនត្រូវចោទមានសិទ្ធិទទួលបានមេធាវី ហើយត្រូវតែមានក្នុងពេលសាកសួរដោយថៅក្រមស៊ើបសួរ អំពីបទល្មើសឧក្រិដ្ឋ។ តាមនីតិវិធីព្រហ្មទណ្ឌ ក្រៅពីបទល្មើសជាក់ស្តែង ការឃាត់ខ្លួនតម្រូវឲ្យមានដីកាពីអាជ្ញាធរតុលាការ។ ក្នុងសំណុំរឿងនេះ តុលាការកំពូលអះអាងថា ចម្លើយទទួលបានពីការសាកសួរដោយគ្មានវត្តមានមេធាវី ពុំត្រូវទទួលយក។

ជនត្រូវចោទ មានសិទ្ធិនៅស្ងៀមមិននិយាយ (right to silence) និងមិនត្រូវបង្ខំឲ្យឆ្លើយដាក់ បន្ទុកខ្លួនឯងទេ (non-self-incrimination)។